**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**
**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**
ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ
លេខ........................................

# របាយការណ៍

## បូកសរុបលទ្ធផលការងារប្រចាំខែមេសា ឆ្នាំ២០២១

**ក-អំពីកម្លាំង៖**

សរុបរួមចំនួន៖ ០៥នាក់ (ស្រី០២នាក់) អវត្តមាន៖ ០០

**ខ-សកម្មភាព និងលទ្ធផលការងារ**

ខ.១-កិច្ចប្រជុំពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាងគោលនយោបាយ និងបទដ្ឋានគតិយុត្តិនានា

<u>សកម្មភាពក្នុងស្រុក</u>

- **ថ្ងៃទី០២ ខែមេសា ឆ្នាំ២០២១** លោកជំទាវ ឧត្តមសេនីយ៍ទោ អគ្គលេខាធិការរង បានអញ្ជើញចូលរួមកិច្ចពិភាក្សាតាមប្រព័ន្ធអនឡាញស្តីពី "លទ្ធផលនៃការអនុវត្តសកម្មភាពប្រចាំត្រីមាសទី១ ឆ្នាំ២០២១ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាមួយគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តសៀមរាប។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពី លោកជំទាវឧត្តមសេនីយ៍ឯក វេជ្ជ.ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ ឯកឧត្តម ឧត្តមសេនីយ៍ទោ កែវ សុវណ្ណារ៉ា អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការ បង្ការ ទប់ស្កាត់ ឯកឧត្តម ឧត្តមសេនីយ៍ត្រី តែ សុថារ៉េត អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការ អនុវត្តច្បាប់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ លោកស្រី យូ សុភា អភិបាលរងខេត្តសៀមរាប ក្រុមការងារ គ.ខ.ប.ជ លោកស្រីឧត្តមសេនីយ៍ត្រី ជាស្នងការរងខេត្ត លោកមេបញ្ជាការរងកងរាជអាវុធហត្ថខេត្ត តំណាងពីមន្ទីរពាក់ព័ន្ធ អភិបាលរងស្រុកជុំវិញខេត្ត តំណាងពីអង្គការដៃគូរអភិវឌ្ឍនានា និងតំណាងពីរដ្ឋបាល ខេត្តសៀមរាប។

- **ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ទទួលបន្ទុកក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ បានចូលរួមតាមប្រព័ន្ធអនឡាញលើប្រធានបទ "សិក្ខាសាលាពិគ្រោះយោបល់ SOMTC លើផែនការការងារ អាស៊ាន-អូស្ត្រាលី ២០២០-២០២៣ ស្តីពីការងារប្រឆាំងអំពើជួញដូរ មនុស្ស" ដែលមានអ្នកចូលរួមសរុបចំនួន៩២នាក់ ពីសមាជិកអាស៊ានទាំង១០ និង តំណាង ASEAN-ACT Australia, ASEAN-ACT Cambodia, ASEAN-ACT Philippine, ASEAN-ACT Vietnam និង Asia Foundation។ កិច្ចប្រជុំនេះប្រព្រឹត្តទៅក្រោមការ ដឹកនាំសម្រប

សម្រួលដោយប្រធាន SOMTC Philippine ។ សមាសភាពភាគីកម្ពុជារួមមាន៖ លោកជំទាវ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការ សហប្រតិបត្តិការអន្តរជាតិជាសមាជិកានៃក្រុមការងារក្រសួងមហាផ្ទៃ ទទួលបន្ទុក ឧក្រិដ្ឋកម្ម ឆ្លងដែនក្នុងក្របខណ្ឌអាស៊ាន (SOMTC) និងជាមន្ត្រីបង្គោលនៃ ផែនការងារប្រឆាំងការជួញដូរមនុស្ស លោកឧត្តមសេនីយ៍ត្រី តែ សុថារ៉េត អគ្គលេខាធិការរង ទទួលបន្ទុកក្រុម ជំនួយកិច្ចការអនុវត្តច្បាប់ និងជាសមាជិកានៃក្រុមការងារក្រសួងមហាផ្ទៃ ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន ក្នុងក្របខណ្ឌអាស៊ាន (SOMTC) លោកឧត្តមសេនីយ៍ឯក សុខ រស្មី អនុប្រធាននាយកដ្ឋានកណ្តាលនគរបាល យុត្តិធម៌ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ជាសមាជិកនៃក្រុមការងារ ក្រសួងមហាផ្ទៃ ទទួលបន្ទុក ឧក្រិដ្ឋកម្មឆ្លងដែន ក្នុងក្របខណ្ឌអាស៊ាន (SOMTC) និងជាមន្ត្រីបង្គោល នៃផែនការងារ ប្រឆាំងការជួញដូរមនុស្ស លោកវរសេនីយ៍ទោ ភូ សង្វាត នាយរងការិយាល័យការពារអនីតិជន នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងជាសមាជិកក្រុមការងារ GID-CNP-FBI Task Force លោក ណៃ ឈួន និងលោក អ៊ុន វុឌ្ឍី តំណាងមកពី ASIAN ACT Cambodia ។

ជាលទ្ធផលអង្គប្រជុំបានសម្រេចកម្មវិធីការងារដូចខាងក្រោម÷

១. ភាគីប្រុយណេ នឹងក្លាយជាប្រធានអណត្តិបន្ត SOMTC ASEAN

២. ពិនិត្យផែនការសកម្មភាព ២០២០ - ២០២៣ និងមានដាក់បញ្ចូលធាតុចូល ដែលបាន ពីការចូលរួមពីប្រទេសជាសមាជិកទាំង១០

៣. ឯកសារ APTIP គឺជាឯកសារយោងសម្រាប់កិច្ចប្រជុំ ASEAN ACT ក៏ដូចជាដាក់បញ្ចូល ទៅក្នុងផែនការការងារ

៤. SOMTC Philippine នឹងធ្វើការចងក្រងសមាជិកបង្គោលទាំងអស់ និងជម្រុញឱ្យកិច្ច សហការនៅក្នុងតំបន់កាន់តែមានប្រសិទ្ធិភាពដែលសំដៅដល់ការជួយជនរងគ្រោះទាន់ពេលវេលា ជាពិសេសជនរងគ្រោះជាស្ត្រី និងកុមារ។

- **ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១** ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ដែលដឹកនាំដោយ លោកជំទាវឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង លោកឧត្តមសេនីយ៍ត្រី អ៊ិន មាន ប្រធានក្រុមជំនួយកិច្ចការបានអញ្ជើញបើកកិច្ចប្រជុំផ្ទៃក្នុងប្រចាំសប្តាហ៍ តាមរយៈប្រព័ន្ធអនឡាញ (zoom)។ ខ្លឹមសារនៃកិច្ចប្រជុំបានផ្តោតសំខាន់ទៅលើចំនុចមួយចំនួនដូចខាងក្រោម៖

- បច្ចុប្បន្នភាពនៃការងារក្នុងក្រុម កំឡុងពេលរីករាលដាលនៃជំងឺកូវីត១៩
- ពិភាក្សាអំពីចំនុចចាប់ផ្តើមនៃការបង្កើតវគ្គបណ្តុះបណ្តាល និងសិក្ខាសាលារយៈពេលខ្លីតាមប្រព័ន្ធអនឡាញស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ស្វែងរកនូវធាតុចូលសំខាន់ៗនៃការបង្កើតវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ដែលមានការចូលរួមយោបល់របស់ក្រុមការងារ

- បែងចែកការងារធ្វើតាមរយៈប្រព័ន្ធអនឡាញ ដោយស្វែងរកនូវខ្លឹមសារ និងមេរៀនដែលចាំបាច់ដើម្បីបញ្ចូលទៅក្នុងការរៀបចំវគ្គបណ្តុះបណ្តាល
- ស្វែងរកកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ដើម្បីចូលរួមសកម្មភាពផ្សេងៗ

-**ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១** ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ បានបើកកិច្ចប្រជុំផ្ទៃក្នុងបន្តតាមរយៈប្រព័ន្ធ Video Conference (Zoom) ដែលខ្លឹមសារនៃកិច្ចប្រជុំគឺបានផ្តោតសំខាន់ទៅលើចំនុចសំខាន់ៗមួយចំនួនដូចខាងក្រោមៈ

- ពន្យល់លម្អិតពីបញ្ហាបច្ចេកទេស ក្នុងការផ្សព្វផ្សាយពត៌មាននៅលើហ្វេសបុកផេក និងតេឡេក្រាមផ្លូវការរបស់ គ.ជ.ប.ជ
- ណែនាំឱ្យស្គាល់ពីហ្វេសបុកផេក និងតេឡេក្រាមផ្លូវការថ្មី របស់ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ
- កំណត់សិទ្ធិឱ្យក្រុមការងារអាចចូលប្រើប្រាស់ផេកបន្ថែមទៀត ដើម្បីជួយសម្រួលក្នុងការផ្សព្វផ្សាយឱ្យទាន់ពេលវេលា
- លទ្ធផលនៃកិច្ចពិភាក្សា និងស្វែងរកដៃគូសហការបន្ថែមទៀតពីបណ្តាអង្គការ និងសង្គមស៊ីវិលផ្សេងៗ ដើម្បីចងក្រងជាមេរៀន និងការចូលរួមសកម្មភាពផ្សេងៗ សម្រាប់វគ្គបណ្តុះបណ្តាលនាពេលខាងមុខ។

- **ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ លោកជំទាវ ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គជបជ បានដឹកនាំភាគីកម្ពុជារួមមាន លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គជបជ លោកជំទាវឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គជបជ និងលោកឧត្តមសេនីយ៍ឯក សុខ វស្នី អនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ និងតំណាងមកពី ASIAN ACT Cambodia ចំនួន ២រូប ចូលរួមសិក្ខាសាលាថ្នាក់តំបន់ដើម្បីគាំទ្រការផ្លាស់ប្តូរចំណេះដឹង និងបទពិសោធន៍ស្តីពីការប្រតិបត្តិមណ្ឌលស្នាក់នៅ នៅក្នុងរដ្ឋជាសមាជិកអាស៊ាន ជាពិសេសនៅក្នុងកំឡុងពេលមានការរីករាលដាលមេរោគកូវីដ-១៩។ សិក្ខាសាលាតាមប្រព័ន្ធវីដេអូនេះ បានរៀបចំដោយ កម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN ACT) សហការជាមួយក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស (MSDHS) ប្រទេសថៃ, ស្ថាប័នទំនាក់ទំនងនៃកិច្ចប្រជុំឧត្តមមន្ត្រី ស្តីពីការងារសង្គមកិច្ច និងអភិវឌ្ឍន៍ (SOMSWD), តំណាងប្រទេសថៃសម្រាប់សិទ្ធិកុមារនៅក្នុងគណៈកម្មាការអាស៊ានទទួលបន្ទុកលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC) និងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីនជាអ្នកដឹកនាំស្ម័គ្រចិត្តលើការងារប្រឆាំងការជួញដូរមនុស្សសម្រាប់ក្រុមការងារទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនក្នុងក្របខណ្ឌអាស៊ាន (SOMTC) និងដោយមានការចូលរួមពីប្រទេសសមាជិកអាស៊ាន អ្នកពាក់ព័ន្ធក្នុងការងាររដ្ឋបាល និងការគ្រប់គ្រងមណ្ឌលស្នាក់នៅ/អាគារស្នាក់នៅ/ជម្រកបណ្តោះអាសន្ន/ជម្រក

សហគមន៍ សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នាយកដ្ឋានអន្តោប្រវេសន៍ និងតំណាង SOMTC, SOMSWD, AICHR, ACWC សរុបចំនួន ២០០រូប ។

គោលបំណងរបស់សិក្ខាសាលាពិគ្រោះ

- បង្ហាញរបកគំហើញសំខាន់ៗពីការសិក្សា និងផ្តល់អនុសាសន៍ទាក់ទិននឹងច្បាប់ គោលនយោបាយ និងការប្រតិបត្តិសម្រាប់ពិចារណា
- ផ្តល់ជូនវេទិកាមួយសម្រាប់ពិភាក្សាការវិវត្ត និងបញ្ហាប្រឈមនានា នៅក្នុងការគាំទ្រជនរងគ្រោះ
- ពង្រឹង ការយល់ដឹង និងចែករំលែកការប្រតិបត្តិល្អនៅក្នុងអភិក្រមផ្អែកលើសិទ្ធិ និងផ្តោតលើជនរងគ្រោះ
- គាំទ្រដល់កិច្ចប្រឹងប្រែងបច្ចុប្បន្នរបស់រដ្ឋជាសមាជិកអាស៊ានក្នុងការជម្រុញសេរីភាពក្នុងការបំលាស់ទី និងការមិនធ្វើទណ្ឌកម្មលើជនរងគ្រោះដោយការជួញដូរ។

ជាលទ្ធផលអង្គប្រជុំបានសម្រេចកម្មវិធីការងារដូចខាងក្រោម÷

១. កិច្ចប្រជុំប្រទេសជាសមាជិកពិភាក្សាឱ្យការអនុវត្តអនុសញ្ញាអាស៊ាន ក្នុងការគិតគូរពីសិទ្ធិរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការគ្រប់គ្រងមណ្ឌលកាន់តែប្រសើរឡើង

២. ជម្រុញការធ្វើអនុស្សារណៈយោគយល់ទ្វេរភាគីនៃប្រទេសជាប់ព្រំដែន ក្នុងការគ្រប់គ្រងជនរងគ្រោះ

៣. កិច្ចប្រជុំបានពិនិត្យឃើញថា ប្រទេសជាសមាជិកទាំងអស់មានបទពិសោធន៍ល្អ និងចំនុចខ្លាំងរៀងៗខ្លួន នៅក្នុងការគ្រប់គ្រងមណ្ឌល

៤. និងបន្តឱ្យមានការពិភាក្សាបន្តទៀត ដើម្បីស្វែងរកចំនុចរួមក្នុងកិច្ចការពារជនរងគ្រោះ។

**ខ.២-ការងារគម្រោង**

- បន្តការតាមដានរាល់បញ្ហាបច្ចេកទេសនានានឹង NGO Referral DB និងធ្វើការតម្រូវការ
- បន្តសិក្សាតម្រូវការចាំបាច់ សម្រាប់អភិវឌ្ឍ NGO Referral DB អោយកាន់តែប្រសើរ
- បញ្ចូលព័ត៌មានពាក់ព័ន្ធនឹង ប៉ុស្តិ៍នគរបាល មណ្ឌលសុខភាព និងព័ត៌មានពាក់ព័ន្ធមួយចំនួនពីក្រសួង កិច្ចការនារី និងក្រសួងសង្គមកិច្ច
- ទទួលព័ត៌មានត្រលប់ពីការធ្វើបច្ចុប្បន្នភាពអង្គការដៃគូចូលរួមសហការ
- រៀបចំកិច្ចប្រជុំជាមួយវិស័យឯកជន ដោយរួមបញ្ចូលទាំងសមាគមន៍ និងសហគ្រាសធំតូចទាំងអស់ដែលពាក់ព័ន្ធនឹងការប្រើប្រាស់កម្លាំងពលកម្ម

## គ-ទិសដៅបន្ត

- ការរៀបចំការងារចងក្រងព័ត៌មានតាមគេហទំព័រសារព័ត៌មាននានា
- តារាងតាមដានបច្ចុប្បន្នភាពអនុស្សរណៈ( ជំរុញការអនុវត្ត MOU ដែលចុះហត្ថលេខារួច និងការផ្តួចផ្តើមអោយមានការចុះអនុស្សរណៈថ្មី)

- ប្រព័ន្ធទិន្នន័យ NGO Referral Database កែ source code ដើម្បីឱ្យមានការចូលរួមអភិវឌ្ឍន៍ពីអ្នកជំនាញខាងក្រៅ
- សិក្សាលើពាក្យគន្លឹះសម្រាប់ប្រើប្រាស់រួមក្នុងការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (terms.ncct.gov.kh)
- ការស្នើកិច្ចប្រជុំលើក្នុងការបញ្ចូលព័ត៌មានបន្ថែមលើប្រព័ន្ធទិន្នន័យ NGO Referral Database ត្រង់ចំនុច (ប៉ុស្តិ៍នគរបាល និងមណ្ឌលសុខភាព)

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០២១

**ប្រធាន**

**ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**

**ចម្លងជូន៖**

-លេខាធិការដ្ឋានរដ្ឋបាលសរុប

-លោកជំទាវអគ្គលេខាធិការរងទទួលបន្ទុក

-លោកជំទាវអគ្គលេខាធិការ

"ដើម្បីជូនជ្រាប" ជាសេចក្តីរាយការណ៍

-ឯកសារ-កាលប្បវត្តិ